# មាតិកា

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 23 ខែ 3 ឆ្នាំ 2000

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២១-៤-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៨ តែងតាំងឯកឧត្តម ខែម ម៉ិននាង ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូណេស៊ី ៧០៩

## II- រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២១-៤-១៩៩៩ -អនុក្រឹត្យលេខ ៣៤ អនក្រ.បក កែតម្រូវទៅលើអនុក្រឹត្យលេខ ៤៦ អនក្រ.បក ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និងពិការ ៧១០
១៩-៤-១៩៩៩ -អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧១៤
២០-៤-១៩៩៩ -អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧១៥
២៣-៤-១៩៩៩ -អនុក្រឹត្យលេខ ១១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧១៦
២៣-៤-១៩៩៩ -អនុក្រឹត្យលេខ ១១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧១៧
២៣-៤-១៩៩៩ -អនុក្រឹត្យលេខ ១១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧១៨
២៣-៤-១៩៩៩ -អនុក្រឹត្យលេខ ១១៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧១៩
២៣-៤-១៩៩៩ -អនុក្រឹត្យលេខ ១១៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧២០

## III- ការងារបណ្តាក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

១៧-៤-១៩៩៩ -ប្រកាសលេខ ៤០៧ ផក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន សេនតិច អ៊ិនដឹស្ទ្រៀល (ខេមបូឌា). លីមីធីតតំណាងដោយលោក ឡូ ពាយសិន បង្កើតរោងចក្រដេរកាបូប នាំចេញ ៧២១
២១-៤-១៩៩៩ -ប្រកាសលេខ ៤៤១ ផក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន ទីចធីរ ឡូឌអេច ខេមបូឌា តំណាងដោយលោក KONG CHIN CHU សញ្ជាតិចិន (តៃវ៉ាន់) បង្កើតរោងចក្រផលិតស្បែកជើងនាំចេញ ៧២៣

***

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .-** តែងតាំងឯកឧត្តម ខែម ម៉ិននាង ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូណេស៊ី ជំនួសលោកជំទាវ ម៉ុក ម៉ារីណា ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

# II- រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ

### អនុក្រឹត្យលេខ ៣៤ អនក្រ.បក

កែតំរូវទៅលើអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីរបបឧបត្ថម្ភ
ចំពោះយោធិនពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និងពិការ

***

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាល ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្គស្លាប់ និងពិការ
- តាមការយល់ព្រមពីគណៈរដ្ឋមន្ត្រីក្នុងប្រជុំពេញអង្គ នាថ្ងៃទី ១២ ខែ មិនា ឆ្នាំ ១៩៩៩

### សំរេច

**មាត្រា ១ .-** មាត្រា៣ មាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.ប ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ត្រូវបានកែតំរូវដូចតទៅ :

- មាត្រា ៣ ថ្មី : ការវាយតំលៃប្រភេទថ្នាក់ពិការ គឺត្រូវធ្វើឡើងដោយក្រុមប្រឹក្សាវាយតំលៃមួយ របស់ក្រសួងការពារជាតិ ដោយផ្អែកតាមប្រកាសរបស់អន្តរក្រសួង ដែលមានសមាសភាព :
  - ក្រសួងការពារជាតិ

- ក្រសួងសុខាភិបាល
- ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

- មាត្រា ៦ ថ្មី : យោធិនទាំងពីរភេទ ដូចមានចែងក្នុងមាត្រា ២ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ :

ក-ចំពោះយោធិនពិការប្រភេទ "ក" គ្រប់កំរិតថ្នាក់ ៖

១- ក្រោយពេលព្យាបាលជំងឺរបួសជាសះស្បើយ និងមានពនឹង ត្រូវបានទទួលរបបឧបត្ថម្ភប័ណ្ណសុខភាពនៅមជ្ឈមណ្ឌលប័ណ្ណសុខភាពតាមរយៈពេលកំណត់ និងតាមកំរិតថ្នាក់ពិការ គឺ ៖

- កំរិតថ្នាក់ ១ បានអនុញ្ញាតឲ្យសំរាកប័ណ្ណសុខភាព ចំនួន ៩០ថ្ងៃ
- កំរិតថ្នាក់ ២ បានអនុញ្ញាតឲ្យសំរាកប័ណ្ណសុខភាព ចំនួន ៦០ថ្ងៃ
- កំរិតថ្នាក់ ៣ បានអនុញ្ញាតឲ្យសំរាកប័ណ្ណសុខភាព ចំនួន ៤៥ថ្ងៃ
- កំរិតថ្នាក់ ៤ បានអនុញ្ញាតឲ្យសំរាកប័ណ្ណសុខភាព ចំនួន ៣០ ថ្ងៃ

២- យោធិនពិការ ប្រសិនបើនៅបន្តការងារក្នុងកងយោធពលខេមរភូមិន្ទ ក៏បានទទួលរបបឧបត្ថម្ភជំនួយមុខរបួសបន្ថែមជាប្រចាំខែ ដោយគិតជាសមាមាត្រភាគរយនៃបៀវត្សសរុបប្រចាំខែផ្ទាល់ខ្លួន និងតាមកំរិតថ្នាក់ពិការ គឺបន្ថែមលើប្រាក់បៀវត្សប្រចាំខែផ្ទាល់ខ្លួន ។

- កំរិតថ្នាក់ ១ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៤៥ភាគរយ នៃប្រាក់បៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។
- កំរិតថ្នាក់ ២ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៤០ភាគរយ នៃប្រាក់បៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។
- កំរិតថ្នាក់ ៣ បានទទួលរបបឧបត្ថម្ភទឹកប្រាក់ចំនួនស្មើនឹង ៣៥ភាគរយ នៃប្រាក់បៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។
- កំរិតថ្នាក់ ៤ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ស្មើនឹង ៣០ភាគរយ នៃប្រាក់បៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

៣- យោធិនពិការ ដែលក្រសួងការពារជាតិសំរេចឲ្យចេញពីជួរកងយោធពលខេមរភូមិន្ទ ត្រូវបានទទួលរបបឧបត្ថម្ភប្រាក់អតីតភាពបំរើការងារមិនលើសពី ២៤ខែ ដោយគិតរយៈពេលបំរើកងយោធពលខេមរភូមិន្ទក្នុង ១ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីត

ភាព ចំនួន ២ខែ ។ ចំពោះយោធិនពិការ ដែលបំរើកងទ័ពមិនទាន់គ្រប់រយៈពេល ១ឆ្នាំ ហើយត្រូវពិការក៏ត្រូវបានទទួលប្រាក់អតីតភាព ចំនួន ២ខែ ដែរ ។

៤- យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភមួយលើកដំបូងស្មើនឹងទឹកប្រាក់ ចំនួន ៖

- កំរិតថ្នាក់ ១ ទទួលទឹកប្រាក់សរុប ចំនួន ១២ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។
- កំរិតថ្នាក់ ២ ទទួលទឹកប្រាក់សរុប ចំនួន ១០ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។
- កំរិតថ្នាក់ ៣ ទទួលទឹកប្រាក់សរុប ចំនួន ០៨ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។
- កំរិតថ្នាក់ ៤ ទទួលទឹកប្រាក់សរុប ចំនួន ០៦ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។

៥- បានបន្តទទួលបើកប្រាក់បៀវត្សសរុបប្រចាំខែ ហើយបៀវត្សសរុបនោះត្រូវគិតតាមឋានន្តរសក្តិចុងក្រោយ មុនពេលសំរេចឲ្យចេញពីជួរកងយោធពលខេមរភូមិន្ទ និងចំនួនកូននៅក្នុងបន្ទុកជាក់ស្តែងរបស់យោធិនពិការ ។

៦- យោធិនពិការ ដែលរស់នៅក្នុងមណ្ឌលយោធិន ដែលចេញពីជួរកងយោធពលខេមរភូមិន្ទ ត្រូវបានបន្ថែមនូវប្រាក់ឧបត្ថម្ភជំនួយមុខរបួសជារៀងរាល់ខែ ដោយគិតជាសមាមាត្រលើប្រាក់បៀវត្សសរុបផ្ទាល់ខ្លួនប្រចាំខែដូចខាងក្រោម ៖

- កំរិតថ្នាក់១ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើ ១០០ភាគរយ
- កំរិតថ្នាក់២ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើ ៨០ភាគរយ
- កំរិតថ្នាក់៣ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើ ៦០ភាគរយ
- កំរិតថ្នាក់៤ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើ ៥០ភាគរយ

៧- យោធិនពិការកំរិតថ្នាក់១ បានទទួលរបបឧបត្ថម្ភអ្នកបំរើផ្ទាល់ខ្លួនមួយនាក់ ហើយអ្នកបំរើនោះ ត្រូវបានទទួលជាប្រចាំខែរហូតដល់យោធិននោះស្លាប់ ស្មើនឹងបៀវត្សផ្ទាល់ខ្លួនរបស់យោធិន មានឋានន្តរសក្តិជាពលទោ ។

ខ- យោធិនពិការប្រភេទ “ខ” គ្រប់កំរិតថ្នាក់

១- យោធិនពិការប្រភេទ “ខ” ដែលក្រសួងការពារជាតិសំរេចចេញពីជួរកងយោធពលខេមរភូមិន្ទ នឹងបានទទួលប្រាក់ឧបត្ថម្ភអតីតភាពបំរើការងារមិនលើសពី ៨ខែ ដោយគិតរយៈពេលបំរើកងយោធពលខេមរភូមិន្ទ ដូចក្នុងចំណុច “ក៣” ខាងលើ ។

២- យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភតាមកំរិតថ្នាក់ពិការជាប្រចាំ តាមកំរិតសមាមាត្រភាគរយនៃប្រាក់បៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការ ៖

- កំរិតថ្នាក់១ បានទទួលទឹកប្រាក់សរុបស្មើនឹង ៩០ភាគរយ នៃបៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។
- កំរិតថ្នាក់២ បានទទួលទឹកប្រាក់សរុបស្មើនឹង ៨០ភាគរយ នៃបៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។
- កំរិតថ្នាក់៣ បានទទួលទឹកប្រាក់សរុបស្មើនឹង ៧០ភាគរយ នៃបៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។
- ត្រូវបានទទួលឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬ ប្ដី កូន ដូចយោធិនពិការប្រភេទ "ក" ។

គ- យោធិនពិការប្រភេទ "ក"និង"ខ" គ្រប់កំរិតថ្នាក់ត្រូវបានទទួលរបបឧបត្ថម្ភបន្ថែម៖

១- នារាល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងថ្ងៃបុណ្យខួបរំលឹកគុណយោធិនពលី ពិការ (កំណត់ថ្ងៃបុណ្យភ្ជុំបិណ្ឌ) ត្រូវបានទទួលរបបឧបត្ថម្ភស្មើនឹងទឹកប្រាក់ឧបត្ថម្ភថ្ងៃបុណ្យរបស់មន្ត្រីរាជការកំពុងធ្វើការងារ ។

២- ពេលមានជំងឺ របួស ឬពេលរបួសរើ ត្រូវបានទទួលសង្គ្រោះព្យាបាលលុះជាសះស្បើយនៅតាមមន្ទីរពេទ្យរដ្ឋ ដោយឥតគិតថ្លៃ ។

៣- យោធិនពិការទាំងពីរភេទ ត្រូវបានទទួលស្ដារលទ្ធភាពពលកម្ម និងជួយបណ្ដុះបណ្ដាលមុខវិជ្ជាជីវៈនៅតាមមជ្ឈមណ្ឌលរបស់រដ្ឋដោយឥតគិតថ្លៃ និង ត្រូវបានក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជួយសំរួលដោះស្រាយមុខរបរតាមលទ្ធភាព និងសមត្ថភាពរបស់យោធិនពិការ ។

៤- ចំពោះយោធិននារីពិការ ត្រូវបានឧបត្ថម្ភជាបន្ថែមនូវការធានារ៉ាប់រងសង្គម ដូចជាស្ត្រីដែលកំពុងបំរើការងាររាជការដែរ ។

៥- ចំពោះយោធិនពិការ ដែលនៅបំរើការងារនៅពេលគ្រប់លក្ខណៈសម្បត្តិចូលនិវត្តន៍ ត្រូវផ្ទេរទៅក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីដោះស្រាយប្រាក់សោធននិវត្តន៍វិញ ។

មាត្រា៧ ថ្មី : រាល់ការចំណាយលើរបបឧបត្ថម្ភ ដូចជាបានចែងក្នុងមាត្រា៥ និង៦ ត្រូវទទួលបន្ទុក ដោយថវិការដ្ឋ ក្រសួងការពារជាតិជាអ្នកទទួលបន្ទុក ដោះស្រាយដូចខាងក្រោម ៖

- ការចំណាយសំរាប់បូជា ឬ បញ្ចុះសព

- ការចំណាយសំរាប់ឧបត្ថម្ភជូនគ្រួសារយោធិនពលី មរណៈ បង្កស្លាប់មួយលើកដំបូង ។
- ការចំណាយសំរាប់ឧបត្ថម្ភប៉ប៉នសុខភាពយោធិនពិការ ។
- ការចំណាយសំរាប់ឧបត្ថម្ភ ប្រាក់អតីតភាពការងាររបស់យោធិនពិការ មុនពេលសំរេចចេញពីជួរកងយោធពលខេមរភូមិន្ទ ។
- ការចំណាយសំរាប់ឧបត្ថម្ភជំនួយមុខរបរសរបស់យោធិនពិការ នៅបន្តការងារក្នុងកងយោធពលខេមរភូមិន្ទ ។
- ការដោះស្រាយប្រាក់បៀវត្សសរុប ០៣ខែ មុនពេលផ្ទេរយោធិនពិការទៅក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្នុងរយៈពេលរង់ចាំ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បំពេញសំណុំលិខិតបន្តដោះស្រាយប្រាក់ឧបត្ថម្ភ ។ ក្រៅពីរបបឧបត្ថម្ភដែលក្រសួងការពារជាតិទទួលបន្ទុកដោះស្រាយ គឺក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជាអ្នកទទួលបន្ទុកដោះស្រាយបន្ត ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងស្ថាប័ន ឬ ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១១២ អនក្រ.តត

### ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃ២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- តំលើងលោក ឡាយ យ៉េម បច្ចុប្បន្នលេខាទី១ នៃស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋគុយបា ជាទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋគុយបា ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១១៣ អនក្រ.តត

### ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

មាត្រា ១ .- ត្រូវបានតែងតាំងលោក អ៊ឹម ចាន់ថុល ជាអគ្គនាយករង នៃអគ្គនាយដ្ឋានចំការកៅស៊ូ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ១១៤ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនអង្គការជាតិ និងតំណាង ដែលបានជួយអភិវឌ្ឍន៍ការងារយុត្តិធម៌នៅខេត្តកំពង់ស្ពឺ ដូចជាជួយកសាងអាគារពន្ធនាគារថ្មី

អាគារធ្វើការថ្មីផ្តល់សំភារៈបំរើការងារ សំភារៈបំរើជីវភាពពិរុទ្ធជន និងការងារបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ។ល។ ចំណាយអស់ទឹកប្រាក់សរុប ចំនួន ២៩៨.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាស ស្ថាបនាជាតិ :**

១- ទីភ្នាក់ងារអូស្ត្រាលី ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AUSAID)

២- គំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា (CCJAP)

**ខ-មេដាយសំរិទ្ធ ស្ថាបនាជាតិ :**

១- លោក Philip Mc INERNEY ទីប្រឹក្សាប៉ូលីស

២- លោកស្រី Lyn KEOGH ទីប្រឹក្សាពន្ធនាគារ

៣- លោកស្រី Gloria CHRISSTIE ទីប្រឹក្សាផ្នែកសុខភាព

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៦១៥ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនជប៉ុន ០២រូប ដែលបានជួយកសាងសាលារៀននៅក្នុងខេត្តកំពត ដូចមានរាយនាមខាងក្រោមនេះ ៖

១- លោកស្រី MARIKO OKAMURA ប្រធានអង្គការ ASAC បានជួយកសាងអាគារសិក្សាចំនួន ១១ខ្នង មាន ៧៧បន្ទប់ ចំណាយអស់ទឹកប្រាក់ចំនួន ៤៣២.២៦៣ ដុល្លារអាមេរិក ។

២- លោក HIDEAKI SHINADA ប្រធានសហជីព AJINOMOTO បានជួយកសាងអាគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ ចំណាយអស់ទឹកប្រាក់ចំនួន ៣៣.០០០ ដុល្លារអាមេរិក ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១១៦ អនក្រ.តត

### ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនបរទេស ០២រូប ដែលបានស្វែងរកជំនួយសំរាប់ស្តារឲ្យដំណើរការឡើងវិញ នូវកំពង់ចំឡងនៅកម្ពុជា ចំណាយអស់ទឹកប្រាក់សរុបចំនួន ១៥លាន ដុល្លារអាមេរិក ដែលជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលដាណឺម៉ាក ដូចមានរាយនាមខាងក្រោមនេះ ៖

១- ឯកឧត្តម Niels Kaas Dyrlund c/14 ឯកអគ្គរាជទូតដាណឺម៉ាកប្រចាំព្រះរាជាណាចក្រកម្ពុជា

២- លោក Yasunobu Matoba c/14 ប្រធានប្រតិបត្តិគណៈកម្មការទន្លេមេគង្គ

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១១៧ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនជប៉ុន ដែលបានបរិច្ចាគថវិកាជួយកសាងអាគារសិក្សាមួយខ្នង ទីចាត់ការ និងបណ្ណាល័យ ជូនសាលាបឋមសិក្សាព្រែករកា ក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ចំនួន ៣០.៣៦៥ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ៖

១- លោក JOE NAKANO ប្រធានអង្គការ FIDR ប្រចាំប្រទេសកម្ពុជា

២- ស្ថានឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១១៨ អនក្រ.តត

### ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានមន្ទីរធម្មការ និងសាសនាក្រុងព្រះសីហនុ

សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ប្រគេន និងជូនសប្បុរសជន ០៣រូប ដែលបានរួមដៃគ្នាកសាងសមិទ្ធផលផ្សេងៗក្នុងវត្តអូរចំណារ សង្កាត់អូរឧកញ៉ា ហេង ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ដូចជា ព្រះវិហារ សាលាឆាន់ រោងបាយ ។ល។ ចំណាយអស់ទឹកប្រាក់សរុបចំនួន ១៩៥.៦០០រៀល ៣២.៥១៨ដុល្លារអាមេរិក និង ១៧៥.០០០បាតថៃ ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ ៖

១- ព្រះតេជគុណ ជាច់ មួន ចៅអធិការវត្តអូរចំណារ

២- ឧត្ដមនាវីត្រី ឡៅ វិញ មេបញ្ជាការរងកងទ័ពជើងទឹក

៣- វរនាវីទោ ខួន យោធ ប្រធានសេនាធិការកងទ័ពដែនសមុទ្រ និងជាប្រធានគណៈកម្មការវត្ត

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

# III- ការងារបណ្ដាក្រសួង

## ១.ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៤០៧ ឧក.ប្រក**

***

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ លិខិតលេខ ៦៥២/៩៨ ក.អ.ក ចុះថ្ងៃទី ១៧-៣-១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញ លិខិតលេខ ០២៩ ឈ.អ ចុះថ្ងៃទី ២៧-៣-១៩៩៩ របស់សាលាខេត្តកណ្តាល ស្តីពីការអនុញ្ញាតឲ្យសាងសង់អគាររោងចក្រ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន សេនតិច អ៊ិនឌីស្ទ្រៀល (ខេមបូឌា) លីមីតធីត ចុះថ្ងៃទី ២៣-៣-១៩៩៩

## សំរេច

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន សេនតិច អ៊ិនឌីស្ទ្រៀល (ខេមបូឌា) លីមីតធីត (SANTEX INDUSTRIAL (CAMBODIA) LIMITED) តំណាងដោយលោក **ឡូ តាយសិន** សញ្ជាតិកម្ពុជា ភេទប្រុស អាយុ៥៦ឆ្នាំ អាស័យដ្ឋានផ្ទះលេខ ៧២១ ផ្លូវលេខ ៩៣ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៧៩០២៤ ភព ចុះថ្ងៃទី ២៣-១០-១៩៩៣ បង្កើត "រោងចក្រកាត់ដេរកាបូប នាំចេញ" ដែលមានឈ្មោះថា "រោងចក្រសេនតិច អ៊ិនឌីស្ទ្រៀល (ខេមបូឌា)" មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ៤ ភូមិត្រពាំងឈើនាង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

**ប្រការ ២ :** ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាសមិទ្ធិលទ្ធភាពបង្កើតរោងចក្រផលិតកាបូប ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៣ :** ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

**ប្រការ ៤ :** រោងចក្រនេះ ត្រូវបានអនុញ្ញាតឲ្យ "កាត់-ដេរ កាបូប" ទៅតាមគំរូ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៥ :** រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្មពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួននៅកន្លែងងាយមើលឃើញ នៅខាងមុខរោងចក្រ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្ដាល និង ប្រធានក្រុមហ៊ុន សេនតិច អ៊ិនដីស្ទ្រៀល (ខេមបូឌា) លីមីតធីត ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះ មានអនុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ស៊ុយ សែម

***

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៤៨១ ឧក.ប្រក

***

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្ដីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ លិខិតលេខ ១៥៥/៩៩ ក.អ.ក ចុះថ្ងៃទី ២៣-០១-១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញ លិខិតលេខ ០៩១ ប.ស្ថ. ចុះថ្ងៃទី ១៩-០១-១៩៩៩ របស់ក្រសួងបរិស្ថាន
- បានឃើញ លិខិតលេខ ១៩៧៤ លអ.ស ចុះថ្ងៃទី ២២-៦-១៩៩៨ របស់សាលាក្រុងភ្នំពេញ ស្ដីពីការអនុញ្ញាតឲ្យសាងសង់អាគារផលិតស្បែកជើង

- យោងពាក្យស្នើរបស់ក្រុមហ៊ុន វិចធ័រី ឡុង អេច ខេមបូឌា ចុះថ្ងៃទី ០៥-៤-១៩៩៩

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន វិចធ័រី ឡុង អេច ខេមបូឌា (VICTORY LONG AGE CAMBODIA., LTD) តំណាងដោយលោក KONG , CHIN-CHU សញ្ជាតិចិន (តៃវ៉ាន់) ភេទប្រុស អាយុ ៥៩ឆ្នាំ អាស័យដ្ឋាន No , 320 Peikong Road , Chiayi Citi TAIWAN R.O.C កាន់លិខិតឆ្លងដែនលេខ M11348264 ចុះថ្ងៃទី 27-11-1995 បង្កើត "រោងចក្រផលិតស្បែកជើងនាំចេញ" ដែលមានឈ្មោះថា "រោងចក្រផលិតស្បែកជើង វិចធ័រី ឡុង អេច ខេមបូឌា" មានទីតាំងស្ថិតនៅភូមិក្បាលដំរី សង្កាត់កាកាប ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាសមិទ្ធិលទ្ធភាពបង្កើតរោងចក្រផលិតស្បែកជើង ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះ ត្រូវបានអនុញ្ញាតឲ្យផលិតនូវ "ស្បែកជើង" ទៅតាមគំរូ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្មពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

បណ្ណាល័យរដ្ឋសភាជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ______

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួននៅកន្លែងងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន វិចធ័រី ឡុង អេច ខេមបូឌា ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះ មានអនុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ស៊ុយ សែម

★★★